ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

# គោលនយោបាយជាតិ
# ស្តីពី
# ការអភិវឌ្ឍបៃតង

បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រីក្នុង

សម័យប្រជុំពេញអង្គនាថ្ងៃទី០១ ខែមីនា ឆ្នាំ២០១៣

**រៀបចំដោយ ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍បៃតង**

ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍បៃតង

ក្រសួងបរិស្ថាន

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

# គោលនយោបាយជាតិ

# ស្តីពី

# ការអភិវឌ្ឍបៃតង

បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រី
ក្នុងសម័យប្រជុំពេញអង្គនា ថ្ងៃទី១ ខែមីនា ឆ្នាំ២០១៣
**រៀបចំដោយ ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍បៃតង**

# មាតិកា

ទំព័រ


**១- សេចក្តីផ្តើម**............................................................ ១

**២- ចក្ខុវិស័យ**............................................................ ១

**៣- គោលបំណងនិងគោលដៅ**............................................................ ១

៣.១- គោលបំណង............................................................ ១

៣.២- គោលដៅ............................................................ ២

**៤- យុទ្ធសាស្ត្រ**............................................................ ២

៤.១- កិច្ចសហការនិងសម្របសម្រួលអន្តរស្ថាប័នជាតិនិងអន្តរជាតិ..................... ២

៤.២- ការសិក្សាស្រាវជ្រាវនិងវិភាគទិន្នន័យ............................................ ២

៤.៣- សុខដុមនីយកម្មនៃការអភិវឌ្ឍបៃតងក្នុងសេដ្ឋកិច្ច សង្គម និងវប្បធម៌ .......... ៣

៤.៤- ការអភិវឌ្ឍធនធានមនុស្ស............................................ ៣

៤.៥- ការអភិវឌ្ឍបច្ចេកវិទ្យាបៃតងឲ្យមានប្រសិទ្ធភាព.................................. ៤

**៥- ផែនការសកម្មភាព**............................................................ ៥

៥.១- ការបង្កើតយន្តការ............................................................ ៥

៥.២- ការបង្កើតក្របខ័ណ្ឌគតិយុត្ត............................................ ៥

៥.៣- ការគាំទ្រហិរញ្ញវត្ថុ............................................................ ៥

៥.៤- ការបណ្តុះបណ្តាលធនធានមនុស្ស............................................ ៥

៥.៥- ដំណើរការអនុវត្ត............................................................ ៥

**៦- ការតាមដានត្រួតពិនិត្យនិងការវាយតម្លៃ**............................................ ៥

**៧- សេចក្តីសន្និដ្ឋាន**............................................................ ៦

**សន្ទានុក្រម**............................................................ I

## ១. សេចក្តីផ្តើម

ព្រះរាជាណាចក្រកម្ពុជា បានរៀបចំក្របខ័ណ្ឌច្បាប់សម្រាប់អនុវត្តការអភិវឌ្ឍបៃតង រួមមាន ផែនទីបង្ហាញផ្លូវអភិវឌ្ឍន៍បៃតងជាតិ អនុស្សរណៈនៃការយោគយល់គ្នាស្តីពីកិច្ចសហប្រតិបត្តិការលើការអភិវឌ្ឍបៃតងជាមួយវិទ្យាស្ថានអភិវឌ្ឍន៍បៃតងសកលនៃសាធារណរដ្ឋកូរ៉េ ព្រះរាជក្រឹត្យស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍បៃតង អនុក្រឹត្យស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍បៃតង និងច្បាប់ស្តីពីការអនុម័តយល់ព្រមឲ្យព្រះរាជាណាចក្រកម្ពុជាចូលជាសមាជិកនៃកិច្ចព្រមព្រៀងស្តីពីការបង្កើតវិទ្យាស្ថានអភិវឌ្ឍន៍បៃតងសកល។

ការអភិវឌ្ឍបៃតងកំពុងជំរុញសមាហរណកម្មស៊ីជម្រៅរបស់ព្រះរាជាណាចក្រកម្ពុជាទៅក្នុងក្របខ័ណ្ឌតំបន់ និងពិភពលោក ដែលជួយរួមចំណែករក្សាស្ថិរភាពនយោបាយ និងស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច ពិសេសវិស័យសេដ្ឋកិច្ច បរិស្ថាន សង្គមកិច្ច និងវប្បធម៌ ដែលដើរទន្ទឹមគ្នាឆ្ពោះទៅកាន់សុខដុមនីយកម្ម និរន្តរភាព និងតុល្យភាពរវាងគ្នា ព្រមទាំងលើកកម្ពស់ការអភិវឌ្ឍសេដ្ឋកិច្ចបៃតងដែលរក្សាការបំភាយកាបូនឲ្យនៅកម្រិតទាប ឆ្ពោះទៅកាន់ការកសាងសង្គមដែលបញ្ចេញកាបូនតិច ដើម្បីជាវិធានការកាត់បន្ថយឧស្ម័នផ្ទះកញ្ចក់បន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ និងកាត់បន្ថយភាពក្រីក្រស្របតាមគោលដៅរបស់រាជរដ្ឋាភិបាលក្នុងការកាត់បន្ថយភាពក្រីក្រឲ្យបាន១%ក្នុង១ឆ្នាំ។

លើសពីនេះទៀត សំដៅរួមចំណែកដល់កិច្ចការពារបរិស្ថាន ការគ្រប់គ្រងធនធានធម្មជាតិ ការអភិរក្សជីវៈចម្រុះ និងព្រៃឈើ ការរក្សាគុណភាពទឹក ដី ខ្យល់ និងសុវត្ថិភាពប្រព័ន្ធអេកូឡូស៊ីប្រកបដោយប្រសិទ្ធភាព និងតាមទិសដៅរបស់អង្គការសហប្រជាជាតិស្តីពី "**អនាគតដែលយើងចង់បាន**" ដែលរាជរដ្ឋាភិបាលបាន និងកំពុងអនុវត្តរាល់ថ្ងៃ លើវិស័យជលផលនិងវិស័យព្រៃឈើ ការប្រើប្រាស់ថាមពលនិងទឹកដោយសន្សំសំចៃ ការប្រើប្រាស់ថាមពលកកើតឡើងវិញ ប្រសិទ្ធភាពប្រើប្រាស់ធនធានធម្មជាតិក្នុងការទ្រទ្រង់ជីវភាពរស់នៅរបស់ប្រជាជន និងការអនុវត្តនយោបាយចាស់ សកម្មភាពថ្មីលើវិស័យដីធ្លី ដើម្បីថែរក្សាធនធានធម្មជាតិជូនអ្នកជំនាន់ក្រោយ ដោយដើរទន្ទឹមនឹងការអភិវឌ្ឍសេដ្ឋកិច្ចជាតិ។

គោលការណ៍អភិវឌ្ឍបៃតង គឺធ្វើឲ្យមានតុល្យភាពនៃការអភិវឌ្ឍសេដ្ឋកិច្ច ជាមួយនឹងបរិស្ថាន សង្គម និងវប្បធម៌ ដើម្បីសម្រេចគោលដៅអភិវឌ្ឍប្រកបដោយចីរភាព។

ដើម្បីទាក់ទាញលំហូរហិរញ្ញប្បទាន បច្ចេកវិទ្យាបៃតង និងវិនិយោគិនបរទេស រាជរដ្ឋាភិបាលដាក់ចេញនូវគោលនយោបាយជាតិស្តីពីការអភិវឌ្ឍបៃតង ដោយមានចក្ខុវិស័យ គោលបំណងនិងគោលដៅ យុទ្ធសាស្ត្រ និងផែនការសកម្មភាពស្របតាមបរិបទកម្ពុជា។

## ២. ចក្ខុវិស័យ

គោលនយោបាយជាតិនេះមានចក្ខុវិស័យធ្វើឲ្យមានតុល្យភាពនៃការអភិវឌ្ឍសេដ្ឋកិច្ចជាមួយនឹងបរិស្ថាន សង្គម វប្បធម៌ និងការប្រើប្រាស់ធនធានធម្មជាតិប្រកបដោយចីរភាព តាមរយៈការបញ្ជ្រាប ការបន្ស៊ី ការបន្សាំ និងធ្វើឲ្យមានសុខដុមនីយកម្មរវាងគោលការណ៍អភិវឌ្ឍបៃតងនិងគោលនយោបាយជាតិ។

## ៣. គោលបំណងនិងគោលដៅ

### ៣.១. គោលបំណង

គោលនយោបាយជាតិនេះមានគោលបំណងលើកកម្ពស់សុខុមាលភាពនិងជីវភាពរស់នៅរបស់ប្រជាជនទាំងអស់ ប្រកបដោយសុខដុមនីយកម្មជាមួយនឹងសុវត្ថិភាពអេកូឡូស៊ី តាមរយៈការអភិវឌ្ឍបៃតងផ្តោតលើសេដ្ឋកិច្ចបៃតង សេដ្ឋកិច្ចខៀវ ការការពារបរិស្ថាន ប្រព័ន្ធសុវត្ថិភាពសង្គម និងការរក្សាអត្តសញ្ញាណវប្បធម៌ជាតិ។

៣.២- គោលដៅ

- ធ្វើការអភិវឌ្ឍសេដ្ឋកិច្ចប្រកបដោយគុល្យភាពជាមួយបរិស្ថាន សង្គម និងវប្បធម៌
- បង្កើតបរិយាកាសអំណោយផលសម្រាប់អភិវឌ្ឍន៍បៃតងប្រកបដោយសមធម៌ តុល្យភាព ភាតរភាព និងគុណភាពក្នុងប្រព័ន្ធសេដ្ឋកិច្ច សង្គម និងអេកូឡូស៊ី ដែលរក្សាបាននូវតម្លៃវប្បធម៌ជាតិ
- ធ្វើការគ្រប់គ្រងឲ្យមានប្រសិទ្ធភាពលើសិទ្ធិទទួលបានការគ្រប់គ្រងធនធានទឹកនិងអនាម័យ សិទ្ធិទទួលបានសន្តិសុខស្បៀងនិងសុវត្ថិភាពចំណីអាហារ សិទ្ធិទទួលបានការអភិវឌ្ឍ ការអភិរក្សព្រៃឈើនិងធនធានទឹកចម្រុះ និងការប្រើប្រាស់ដីប្រកបដោយនិរន្តរភាព សិទ្ធិទទួលបានថាមពលកកើតឡើងវិញនិងប្រសិទ្ធភាពថាមពល សិទ្ធិទទួលបានព័ត៌មាន ចំណេះដឹង និងបំណិន សិទ្ធិទទួលបានមធ្យោបាយបម្រើឲ្យជីវភាពសង្គមនិងបរិស្ថានកាន់តែល្អប្រសើរ និងសិទ្ធិទទួលបានហិរញ្ញវត្ថុក្នុងការបង្កើតអាជីវកម្មខ្នាតតូច មធ្យម និងការវិនិយោគ
- លើកកម្ពស់ការអប់រំនិងបណ្តុះបណ្តាលលើការងារអភិវឌ្ឍន៍បៃតង
- ពង្រឹងការផ្លាស់ប្តូរព័ត៌មាន ចំណេះដឹង បទពិសោធល្អៗ បច្ចេកទេស បច្ចេកវិទ្យា និងការវិនិយោគទាក់ទងនឹងការងារបៃតង
- ជំរុញកិច្ចសហប្រតិបត្តិការអភិវឌ្ឍបៃតងក្នុងក្របខ័ណ្ឌថ្នាក់ក្រោមជាតិនិងថ្នាក់ជាតិ តំបន់ព្រមទាំងពិភពលោក។

## ៤- យុទ្ធសាស្ត្រ

ដើម្បីសម្រេចបាននូវគោលបំណងនិងគោលដៅខាងលើ យុទ្ធសាស្ត្រសំខាន់ៗ មានដូចខាងក្រោម៖

### ៤.១- កិច្ចសហការនិងសម្របសម្រួលអន្តរស្ថាប័នជាតិនិងអន្តរជាតិ

ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍បៃតងដែលមានអគ្គលេខាធិការដ្ឋានជាស្ថាប័នសម្របសម្រួលជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ ព្រមទាំងសហការជាមួយអង្គការជាតិនិងអន្តរជាតិនានា វិស័យឯកជន និងដៃគូអភិវឌ្ឍ ត្រូវ៖

- ពិនិត្យរាល់គោលនយោបាយជាតិនិងលិខិតបទដ្ឋានគតិយុត្តនានា ដោយសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ ក្នុងការសម្រេចឲ្យបាននូវការអភិវឌ្ឍសេដ្ឋកិច្ច ដោយដើរទន្ទឹមគ្នានឹងកិច្ចការពារបរិស្ថាន ការគ្រប់គ្រងធនធានធម្មជាតិ ការរីកចម្រើនសង្គម និងការថែរក្សាអត្តសញ្ញាណវប្បធម៌ជាតិ
- ពង្រឹងយន្តការអនុវត្តទាក់ទងនឹងការអភិវឌ្ឍបៃតង ទាំងយន្តការថ្នាក់ជាតិ ទាំងថ្នាក់ក្រោមជាតិ
- គាំទ្រដល់វិស័យឯកជនដែលធ្វើការវិនិយោគនានា ដើម្បីសុវត្ថិភាពអេកូឡូស៊ី គុណភាពជីវិត និងប្រសិទ្ធភាពសេដ្ឋកិច្ចបៃតងដែលរក្សានូវប្រពៃណីទំនៀមទម្លាប់រស់នៅរបស់ប្រជាជន និងរក្សាតម្លៃបេតិកភណ្ឌមនុស្សលោកនិងធម្មជាតិ
- ពង្រឹងសមត្ថភាពអន្តរស្ថាប័នជាតិនិងផ្លាស់ប្តូរបទពិសោធជាមួយស្ថាប័នអន្តរជាតិដែលពាក់ព័ន្ធនឹងអភិវឌ្ឍន៍បៃតង
- ជំរុញលើកទឹកចិត្តការចូលរួមពីសាធារណជនក្នុងការអនុវត្តគោលការណ៍អភិវឌ្ឍន៍បៃតងនៅកម្ពុជា។

### ៤.២- ការសិក្សាស្រាវជ្រាវនិងវិភាគទិន្នន័យ

- បណ្តុះបណ្តាលសមត្ថភាពមន្ត្រីថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ ដើម្បីប្រមូល សិក្សា ស្រាវជ្រាវ និងវិភាគទិន្នន័យនិងព័ត៌មាន ពាក់ព័ន្ធទៅនឹងការអភិវឌ្ឍបៃតង

- រៀបចំវិធីសាស្ត្រសម្រាប់ប្រមូល វិភាគ និងបកស្រាយទិន្នន័យនិងព័ត៌មានពាក់ព័ន្ធទៅនឹងការអភិវឌ្ឍបៃតង
- ធ្វើការសិក្សា ស្រាវជ្រាវ និងវិភាគទិន្នន័យនិងព័ត៌មានពាក់ព័ន្ធទៅនឹងវិស័យអភិវឌ្ឍន៍សំខាន់ៗដទៃទៀតរួមមាន សេដ្ឋកិច្ច បរិស្ថាន សង្គម និងវប្បធម៌
- សិក្សា ស្រាវជ្រាវ និងវាយតម្លៃពីការប្រែប្រួលអាកាសធាតុ ដែលបង្កឲ្យមានផលប៉ះពាល់ដល់សេដ្ឋកិច្ច បរិស្ថាន សង្គម និងវប្បធម៌
- កំណត់សូចនាករសម្រាប់តាមដាន ត្រួតពិនិត្យ និងវាយតម្លៃពីប្រសិទ្ធភាពអនុវត្តគោលនយោបាយ ផែនការយុទ្ធសាស្ត្រ និងផែនការសកម្មភាពស្ដីពីការអភិវឌ្ឍបៃតងជាតិ។

**៤.៣- សុខដុមនីយកម្មនៃការអភិវឌ្ឍបៃតងក្នុងសេដ្ឋកិច្ច សង្គម និងវប្បធម៌**

- កាត់បន្ថយភាពក្រីក្រតាមរយៈការអភិវឌ្ឍបៃតងថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ
- រៀបចំលិខិតបទដ្ឋានទាក់ទងនឹងរូបិយវត្ថុនិងហិរញ្ញវត្ថុបៃតង
- ជំរុញក្រសួង ស្ថាប័នមានសមត្ថកិច្ចចេញវិញ្ញាបនបត្របៃតង ទង់សញ្ញាបៃតង ពានរង្វាន់បៃតង ស្តង់ដាបៃតង ការប្រកួតប្រជែងពាណិជ្ជកម្មបៃតង ទេសចរណ៍បៃតង ម៉ាក្រូ មីក្រូហិរញ្ញវត្ថុបៃតង ឥណទានបៃតង ពន្ធបៃតង និងសេវាការពារប្រព័ន្ធបរិស្ថាន
- ជំរុញលើកទឹកចិត្តដល់សហគ្រាសខ្នាតតូច មធ្យម និងធំ ឲ្យអនុវត្តផលិតកម្មនិងការប្រើប្រាស់ធនធានធម្មជាតិប្រកបដោយចីរភាព
- លើកកម្ពស់និងបញ្ជ្រាបទស្សនាទានបៃតងនៅគ្រប់ស្រទាប់ស្ថាប័នពាក់ព័ន្ធ យេនឌ័រ និងសាធារណជនទូទៅ
- រៀបចំសូចនាករនៃគោលការណ៍អភិវឌ្ឍន៍បៃតង ដើម្បីប្រសិទ្ធភាពអភិវឌ្ឍន៍បៃតង សេដ្ឋកិច្ចបៃតង និងសេដ្ឋកិច្ចខៀវ
- ជំរុញរាល់សកម្មភាពអភិវឌ្ឍន៍ដែលបង្កការខូចខាតដល់បរិស្ថាន ឲ្យងាកទៅរកការអភិវឌ្ឍថ្មីមួយដោយយកគោលការណ៍អភិវឌ្ឍន៍បៃតងជាមូលដ្ឋានគ្រឹះក្នុងការកាត់បន្ថយហេតុប៉ះពាល់អវិជ្ជមានដល់បរិស្ថាន និងសង្គមពីសកម្មភាពអភិវឌ្ឍន៍នានា
- កំណត់គោលដៅកាត់បន្ថយឧស្ម័នផ្ទះកញ្ចក់ ជាពិសេសឧស្ម័នកាបូនិក
- បង្កើតភូមិ ឃុំ និងសហគមន៍បៃតង ដែលបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ និងមានភាពធន់ទ្រាំទៅនឹងអាកាសធាតុ
- រៀបចំវិធីសាស្ត្រនិងកំណត់នូវស្តង់ដា សម្រាប់អនុវត្តការកាត់បន្ថយការបញ្ចេញឧស្ម័នកាបូនិកនៅតាមបណ្ដាសហគ្រាសផលិតខ្នាតតូច មធ្យម និងធំ
- ជំរុញការស្តារឡើងវិញនូវដីរេចរឹល ខ្សោះជីជាតិ និងតំបន់ងាយទទួលរងការខូចខាតបរិស្ថានតាមរយៈការដាំដើមឈើឡើងវិញ ការអភិរក្សព្រៃឈើ ជលផល ជីវៈចម្រុះ និងការបែងចែកតំបន់សម្រាប់ការអភិរក្សនិងការអភិវឌ្ឍ ដោយមានតុល្យភាពទៅវិញទៅមក
- លើកកម្ពស់ឥណទានកាបូនតាមរយៈទីផ្សារលក់កាបូនអន្តរជាតិ ដោយបង្កើនគម្របព្រៃឈើសម្រាប់ជាអាងស្តុកកាបូន
- ជំរុញការអនុវត្តគោលការណ៍កាត់បន្ថយ ប្រើប្រាស់ឡើងវិញ និងកែច្នៃឡើងវិញ ដើម្បីប្រសិទ្ធភាពប្រើប្រាស់ធនធានធម្មជាតិ និងធន់ទ្រាំទៅនឹងអាកាសធាតុ។

**៤.៤- ការអភិវឌ្ឍធនធានមនុស្ស**

- ជំរុញអភិបាលកិច្ចល្អលើការងារអភិវឌ្ឍបៃតង

- ដាក់បញ្ចូលកម្មវិធីសិក្សាស្តីពីការអភិវឌ្ឍបៃតងនៅតាមគ្រឹះស្ថានសិក្សានានា សាលាបណ្តុះបណ្តាលវិជ្ជាជីវៈ និងស្ថាប័នផ្សេងៗ ដើម្បីបង្កើនចំណេះដឹងអំពីការអភិវឌ្ឍបៃតង សុខដុមនីយកម្មរបស់ប្រជាជនជាមួយនឹងធនធានធម្មជាតិ និងផ្តត់គំនិតស្រឡាញ់ភាពបៃតង សម្រាប់ជំនាន់បច្ចុប្បន្ននិងជំនាន់ក្រោយ
- រៀបចំវគ្គសិក្សាបណ្តុះបណ្តាលរយៈពេលខ្លី មធ្យម និងរយៈពេលវែងពាក់ព័ន្ធនឹងការអភិវឌ្ឍបៃតងនៅក្នុងប្រទេស
- ផ្លាស់ប្តូរបច្ចេកទេសអភិវឌ្ឍន៍បៃតងនិងបណ្តុះបណ្តាលមន្ត្រី បុគ្គលិកអំពីការអភិវឌ្ឍបៃតងនៅក្នុងក្របខ័ណ្ឌវិទ្យាស្ថានអភិវឌ្ឍន៍បៃតងសកល(អង្គការGGGI) តំបន់អាស៊ាន និងសហគមន៍អន្តរជាតិ ដើម្បីបង្កើនការយល់ដឹងពីការអភិវឌ្ឍបៃតង និងប្រសិទ្ធភាពអនុវត្តគោលការណ៍អភិវឌ្ឍន៍បៃតង
- ចូលរួមប្រជុំក្នុងសន្និសីទ វេទិកា សិក្ខាសាលា និងកិច្ចប្រជុំនានា ក្នុងកម្រិតជាតិនិងអន្តរជាតិ ព្រមទាំងសន្និសីទអង្គការសហប្រជាជាតិទាក់ទងនឹងការអភិវឌ្ឍប្រកបដោយចីរភាពនិងការអភិវឌ្ឍបៃតង
- រៀបចំសិក្ខាសាលា កិច្ចប្រជុំពិគ្រោះយោបល់ និងកិច្ចពិភាក្សានានាទាក់ទងនឹងការអភិវឌ្ឍបៃតងដោយសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ វិទ្យាស្ថានអភិវឌ្ឍន៍បៃតងសកល(អង្គការGGGI) អង្គការសហប្រជាជាតិ និងដៃគូអភិវឌ្ឍនានា
- រៀបចំនិងអនុវត្តកម្មវិធីអភិវឌ្ឍន៍បៃតង ដើម្បីបង្កើនជំនាញ និងវិជ្ជាជីវៈបៃតង ជូនមន្ត្រីរាជការនិងអ្នកពាក់ព័ន្ធ ដែលជួយជំរុញការសម្រេចបាននូវគោលដៅអភិវឌ្ឍន៍បៃតងនិងការអភិវឌ្ឍប្រកបដោយចីរភាពកម្ពុជា
- បង្កើតកម្មវិធីអប់រំនិងផ្សព្វផ្សាយដើម្បីបង្កើនគុណភាពនិងបរិមាណព័ត៌មានដែលអាចរកបានសម្រាប់ភាគីពាក់ព័ន្ធទាំងអស់
- បង្កើតកម្មវិធីអប់រំនិងផ្សព្វផ្សាយសម្រាប់មន្ត្រី បុគ្គលិកប្រព័ន្ធផ្សព្វផ្សាយអំពីការអភិវឌ្ឍបៃតង ដើម្បីឱ្យពួកគេមានលទ្ធភាពនិងសមត្ថភាពក្នុងការផ្តល់និងទទួលយោបល់ពីការងារអភិវឌ្ឍបៃតងនេះ
- បញ្ជ្រាបគោលការណ៍អភិវឌ្ឍន៍បៃតង រួមមាន ការងារបរិស្ថានបៃតងនិងធនធានធម្មជាតិ ការងារធនធានទឹកនិងអនាម័យ ការងារសន្តិសុខស្បៀងនិងសុវត្ថិភាពចំណីអាហារ ព្រមទាំងការប្រើប្រាស់ដីធ្លីប្រកបដោយនិរន្តរភាព ការងារសេដ្ឋកិច្ចបៃតង ការងារវិនិយោគបៃតង ការងារគមនាគមន៍បៃតង ការងារឧស្សាហកម្មនិងថាមពលបៃតង ការងារទេសចរណ៍បៃតងទៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ
- ធ្វើបច្ចុប្បន្នកម្មនៃការអភិវឌ្ឍសេដ្ឋកិច្ចជាតិដោយផ្អែកលើគោលការណ៍អភិវឌ្ឍន៍បៃតង។

**៤.៥- ការអភិវឌ្ឍបច្ចេកវិទ្យាបៃតងឲ្យមានប្រសិទ្ធភាព**

- ធ្វើការផ្លាស់ប្តូរនិងផ្ទេរបច្ចេកវិទ្យាទាក់ទងនឹងការងារអភិវឌ្ឍន៍បៃតង ជាអាទិ៍ការងារបរិស្ថានបៃតងនិងធនធានធម្មជាតិ ការងារធនធានទឹកនិងអនាម័យ ការងារសន្តិសុខស្បៀងនិងសុវត្ថិភាពចំណីអាហារ ការងារអភិរក្សធនធានព្រៃឈើ ជលផល និងជីវៈចម្រុះ ការប្រើប្រាស់ដីធ្លីប្រកបដោយនិរន្តរភាព ការងារសេដ្ឋកិច្ចបៃតង ការងារសេដ្ឋកិច្ចខៀវ ការងារវិនិយោគបៃតង ការងារគមនាគមន៍ ការងារឧស្សាហកម្មនិងថាមពលបៃតង និងការងារទេសចរណ៍
- គាំទ្រដល់វិស័យឯកជនដែលធ្វើការវិនិយោគនានាលើបច្ចេកវិទ្យាកាត់បន្ថយឧស្ម័នផ្ទះកញ្ចក់ បច្ចេកវិទ្យាកាត់បន្ថយការសាយភាយសារធាតុបំពុលបរិស្ថាន បច្ចេកវិទ្យាសម្រាប់ប្រើប្រាស់

ថាមពលប្រកបដោយប្រសិទ្ធភាព បច្ចេកវិទ្យាអភិវឌ្ឍន៍ស្អាត និងបច្ចេកវិទ្យាសម្រាប់ការកែច្នៃ និងការប្រើប្រាស់ឡើងវិញនូវធនធានដែលបានប្រើរួច

- លើកទឹកចិត្តដល់អ្នកស្រាវជ្រាវដែលរកឃើញនូវបច្ចេកវិទ្យាបៃតងថ្មីឲ្យបន្តការងាររបស់ខ្លួន។

## ៥. ផែនការសកម្មភាព

### ៥.១. ការបង្កើតយន្តការ

រាជរដ្ឋាភិបាលបានបង្កើតក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍បៃតងជាសេនាធិការផ្ទាល់របស់រាជរដ្ឋាភិបាល និងអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍បៃតង ជាសេនាធិការរបស់ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍បៃតង ដែលមានភារកិច្ចក្នុងការសម្របសម្រួល និងពិគ្រោះយោបល់ជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធនឹងការងារអភិវឌ្ឍន៍បៃតង ដោយជួយរាជរដ្ឋាភិបាលក្នុងការបញ្ជ្រាបការអភិវឌ្ឍបៃតងលើគ្រប់វិស័យ ដោយសហការជាមួយអង្គការជាតិនិងអន្តរជាតិ និងវិស័យឯកជន។

### ៥.២. ការបង្កើតក្របខ័ណ្ឌគតិយុត្ត

ក្នុងការអនុវត្តគោលនយោបាយជាតិនេះ ត្រូវរៀបចំឲ្យមានលិខិតបទដ្ឋានគតិយុត្ត ផែនការយុទ្ធសាស្រ្ត ផែនការសកម្មភាព និងកម្មវិធីស្តីពីការអភិវឌ្ឍបៃតង សមស្របតាមវិស័យពាក់ព័ន្ធនានា ដែលកំណត់ពីសកម្មភាពជាក់លាក់ និងការទទួលខុសត្រូវរបស់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងរៀបចំភ្នាក់ងារអភិវឌ្ឍន៍បៃតងនៅថ្នាក់មូលដ្ឋាន ព្រមទាំងពិនិត្យនិងកែសម្រួលលិខិតបទដ្ឋានគតិយុត្តនានាពាក់ព័ន្ធនឹងការអភិវឌ្ឍបៃតង។

### ៥.៣. ការគាំទ្រហិរញ្ញវត្ថុ

ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍បៃតងនិងអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍បៃតង គឺជាយន្តការរៀបចំគោលនយោបាយ ផែនការយុទ្ធសាស្រ្ត កម្មវិធី និងផែនការសកម្មភាពស្តីពីការអភិវឌ្ឍបៃតងព្រមទាំងសម្របសម្រួលជាមួយអង្គការជាតិនិងអន្តរជាតិ និងតាមដានការអនុវត្តគោលនយោបាយទាំងនេះ ហើយរាល់ការចំណាយសម្រាប់ដំណើរការការងារអភិវឌ្ឍន៍បៃតង គឺមានប្រភពផ្គត់ផ្គង់ដោយថវិកាជាតិនិងពីប្រភពផ្សេងៗទៀត។

### ៥.៤. ការបណ្តុះបណ្តាលធនធានមនុស្ស

ដើម្បីធានាប្រសិទ្ធភាពនៃការអនុវត្តគោលនយោបាយជាតិស្តីពីការអភិវឌ្ឍបៃតង ត្រូវយកចិត្តទុកដាក់រៀបចំនិងអនុវត្តគម្រោងកម្មវិធីសិក្សារយៈពេលខ្លី មធ្យម និងវែង ដើម្បីបង្កើនចំណេះដឹងនិងបទពិសោធការងារអំពីការអភិវឌ្ឍបៃតងសម្រាប់អ្នកវិជ្ជាជីវៈជំនាន់ក្រោយ និងដើម្បីអភិវឌ្ឍចំណេះដឹងនិងជំនាញដល់មន្រ្តីទទួលបន្ទុកការងារអភិវឌ្ឍន៍បៃតង។

### ៥.៥. ដំណើរការអនុវត្ត

រាល់យុទ្ធសាស្រ្តទាំងនេះ ត្រូវបានយកមកអនុវត្តក្នុងរយៈពេលខ្លី មធ្យម និងរយៈពេលវែង ដោយមានការពិគ្រោះយោបល់ និងសម្រេចពីក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍បៃតង ដើម្បីធានាប្រសិទ្ធភាពអនុវត្តគោលនយោបាយជាតិស្តីពីការអភិវឌ្ឍបៃតង ដែលស្របទៅនឹងចក្ខុវិស័យរបស់រាជរដ្ឋាភិបាលកម្ពុជា។

## ៦. ការតាមដានត្រួតពិនិត្យនិងការវាយតម្លៃ

ដើម្បីអនុវត្តគោលនយោបាយជាតិនេះ ឲ្យសម្រេចបានជោគជ័យដូចបានរំពឹងទុក ប្រកបដោយប្រសិទ្ធភាពនិងតម្លាភាព ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍បៃតងត្រូវមានប្រព័ន្ធតាមដានត្រួតពិនិត្យ វាយតម្លៃ និងសំណើកែលម្អការអនុវត្ត ដោយផ្តោតលើសូចនាករដូចខាងក្រោម៖

- ក្របខ័ណ្ឌច្បាប់និងស្ថាប័នជាតិស្តីពីការអភិវឌ្ឍបៃតង ត្រូវបានបង្កើតឡើងនិងកែសម្រួលហើយ ប្រព័ន្ធនៃការកំណត់ការគ្រប់គ្រង ការតាមដាន និងការវាយតម្លៃ ត្រូវបានកែលម្អ
- ប្រភពនិងមូលហេតុដែលធ្វើឲ្យពុំមាននិរន្តរភាពរវាងសេដ្ឋកិច្ច បរិស្ថាន សង្គម និងវប្បធម៌ត្រូវបានកំណត់និងវិភាគ
- ការកសាងសមត្ថភាពមន្ត្រីពាក់ព័ន្ធនឹងការងារអភិវឌ្ឍន៍បៃតង ត្រូវបានកែលម្អនិងពង្រឹងបន្ថែម
- កម្រិតលើការអប់រំដល់ផ្នែកសាធារណៈ ឯកជន សង្គមស៊ីវិល និងសាធារណជន អំពីការអភិវឌ្ឍបៃតងត្រូវបានបង្កើតឡើង ហើយការចូលរួមរបស់សាធារណជននៅថ្នាក់មូលដ្ឋាននៅក្នុងសកម្មភាព និងកម្មវិធីផ្សព្វផ្សាយលើការងារអភិវឌ្ឍន៍បៃតងត្រូវលើកទឹកចិត្ត និងជំរុញឲ្យមានការចូលរួម
- ការអភិវឌ្ឍបៃតងនៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ ត្រូវបានកែលម្អ
- ផលប៉ះពាល់ដល់បរិស្ថាន សង្គម និងវប្បធម៌ ដែលបណ្តាលមកពីសកម្មភាពការអភិវឌ្ឍសេដ្ឋកិច្ចត្រូវបានកាត់បន្ថយ។

## ៧. សេចក្តីសន្និដ្ឋាន

រាជរដ្ឋាភិបាលកម្ពុជាបានឲ្យតម្លៃខ្ពស់ទៅលើការអភិវឌ្ឍបៃតង ដើម្បីធានាបាននូវតុល្យភាពរវាងសេដ្ឋកិច្ច បរិស្ថាន សង្គម និងវប្បធម៌។ ការអនុវត្តគោលនយោបាយជាតិស្តីពីការអភិវឌ្ឍបៃតង ដើម្បីកាត់បន្ថយភាពក្រីក្រ បង្កើនកំណើនសេដ្ឋកិច្ច កិច្ចការពារបរិស្ថាននិងគ្រប់គ្រងធនធានធម្មជាតិ ការរីកចម្រើនលូតលាស់និងសុវត្ថិភាពសង្គម និងរក្សាតម្លៃវប្បធម៌ជាតិ។

# សន្ទានុក្រម

**កសិកម្មបៃតង** សំដៅដល់ផលិតកម្មកសិកម្មដែលប្រើបច្ចេកទេសនិងបច្ចេកវិទ្យាដែលមិនបង្កការខូចខាតដល់បរិស្ថាន និងមិនប៉ះពាល់ដល់អាយុជីវិតមនុស្ស សត្វ ដោយប្រើតែសារធាតុសរីរាង្គ(គ្មានសារធាតុគីមី)ដូចជាជីសរីរាង្គ ពូជដំណាំសរីរាង្គ និងធនធានរូបសាស្ត្រសរីរាង្គ(ទឹក ដី ខ្យល់ ភូគព្ភសាស្ត្រ ធម្មជាតិ) សម្រាប់ផលិតកម្មកសិកម្មនិងការបង្កបង្កើនផល។ កសិកម្មបៃតងគឺជួយលើកកម្ពស់សេដ្ឋកិច្ចបៃតង កសិឧស្សាហកម្មបៃតងនិងទេសចរណ៍បៃតង (ទេសចរណ៍ធម្មជាតិឬអេកូទេសចរណ៍)។

**គមនាគមន៍បៃតង** សំដៅដល់ហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូនផ្លូវគោក ផ្លូវទឹក ផ្លូវអាកាស ទូរគមនាគមន៍ និងបណ្តាញថាមពលអគ្គិសនីដែលជួយលើកកម្ពស់ដល់បរិស្ថានបៃតង ដូចជាផ្លូវរថភ្លើង ផ្លូវរថយន្តក្រុងដឹកអ្នកដំណើរ ផ្លូវនាវាចរណ៍ បណ្តាញខ្សែកាបអុបទិក ប្រព័ន្ធផ្កាយរណប បណ្តាញខ្សែបញ្ជូនអគ្គិសនី។

**គោលការណ៍អភិវឌ្ឍន៍បៃតង** សំដៅដល់ការអភិវឌ្ឍដែលមានលក្ខណៈបៃតង ដើម្បីធានាដល់សិទ្ធិទទួលបានពីការអភិវឌ្ឍ រួមមាន ការងារបរិស្ថានបៃតងនិងធនធានធម្មជាតិ ការងារធនធានទឹកនិងអនាម័យការងារ សន្តិសុខស្បៀងនិងសុវត្ថិភាពចំណីអាហារ ការប្រើប្រាស់ដីធ្លីប្រកបដោយនិរន្តរភាព ការងារសេដ្ឋកិច្ចនិងវិនិយោគ ការងារគមនាគមន៍ ការងារឧស្សាហកម្មនិងថាមពល និងការងារទេសចរណ៍បៃតង។

**ថាមពលបៃតង** សំដៅដល់ប្រសិទ្ធភាពថាមពល ពិសេសការផលិត និងការប្រើប្រាស់ថាមពលកកើតឡើងវិញ ដូចជាថាមពលដើរដោយកម្លាំងខ្យល់ ពន្លឺព្រះអាទិត្យ កម្លាំងទឹករលក ជីវឧស្ម័ន ជីវម៉ាស់ ជីវឥន្ធនៈ និងវារីអគ្គិសនី។

**ទង់សញ្ញាបៃតង** សំដៅដល់ទង់បៃតងដែលផ្តល់ដោយក្រសួង ស្ថាប័នពាក់ពន្ធ ដើម្បីលើកទឹកចិត្តដល់សហគ្រាសវិនិយោគិន និងអ្នកប្រើប្រាស់ដោយបានការពារបរិស្ថាន សុវត្ថិភាពប្រព័ន្ធអេកូឡូស៊ី និងធានាបានកំណើនសេដ្ឋកិច្ច ព្រមទាំងគុណភាពជីវិតជូនប្រជាជន។

**ទេសចរណ៍បៃតង** សំដៅដល់ការអភិវឌ្ឍទេសចរណ៍និងអ្នកទេសចរណ៍ដែលមិនបង្កការប៉ះពាល់ដល់និរន្តរភាពបរិស្ថានបៃតងនិងធនធានធម្មជាតិ ដោយរក្សាបាននូវសោភណភាព ទេសភាពធម្មជាតិបៃតង និងប្រព័ន្ធអេកូឡូស៊ី និងបានគិតគូរដល់ការអភិវឌ្ឍសេដ្ឋកិច្ចសង្គម និងរក្សាអត្តសញ្ញាណវប្បធម៌ដោយមានសុខដុមនីយកម្មរវាងការអភិវឌ្ឍ និងការអភិរក្ស ដើម្បីប្រសិទ្ធភាពនៃការប្រើប្រាស់ធនធានធម្មជាតិដ៏កម្រ ដែលត្រូវបន្សល់ទុកជូនអ្នកជំនាន់ក្រោយនូវសម្បត្តិធម្មជាតិសម្រាប់អនាគតរបស់ខ្លួន។

**បច្ចេកវិទ្យាបៃតង** សំដៅដល់ប្រព័ន្ធបច្ចេកទេសនិងបច្ចេកវិទ្យាដែលមិនបង្កឲ្យមានការខូចខាតដល់បរិស្ថាន ដូចជា បច្ចេកវិទ្យាកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ បច្ចេកវិទ្យាកាត់បន្ថយការសាយភាយសារធាតុបំពុលបរិស្ថាន បច្ចេកវិទ្យាសម្រាប់ប្រើប្រាស់ថាមពលប្រកបដោយប្រសិទ្ធភាព បច្ចេកវិទ្យាអភិវឌ្ឍន៍ស្អាត និងបច្ចេកវិទ្យាសម្រាប់ការកែច្នៃនិងការប្រើប្រាស់ឡើងវិញនូវធនធានដែលបានប្រើរួច។

**បរិស្ថានបៃតង** សំដៅដល់បរិស្ថានល្អស្អាតគ្មានជាតិពុលដែលកើតចេញពីការអភិវឌ្ឍស្អាត ការមិនបំពុលបរិស្ថានក្នុងការថែរក្សាគុណភាពទឹក គុណភាពដី និងគុណភាពខ្យល់ សុវត្ថិភាពប្រព័ន្ធអេកូឡូស៊ី ការធានាបានជាអាទិ៍នូវសុវត្ថិភាពចំណីអាហារ ការគ្រប់គ្រងធនធាន ធម្មជាតិ ព្រៃឈើ ធនធានទឹក ប្រកបដោយនិរន្តរភាព ការប្រើប្រាស់ដីប្រកបដោយចីរភាព និងការលើកកម្ពស់សុខុមាលភាពសាធារណៈ ដែលជាកត្តាចម្បងក្នុងការលើកស្ទួយសេដ្ឋកិច្ចបៃតងឲ្យមានតុល្យភាពទៅនឹងចីរភាពបរិស្ថាន សង្គម និងវប្បធម៌។

**ផលិតកម្មនិងការប្រើប្រាស់ប្រកបដោយចីរភាព** សំដៅដល់ប្រសិទ្ធភាពប្រើប្រាស់ធនធានធម្មជាតិដើម្បីបំពេញសេចក្តីត្រូវការផលិតនិងប្រើប្រាស់ក្នុងសេដ្ឋកិច្ច សង្គម ដែលបន្តរក្សានិរន្តរភាពធនធានធម្មជាតិ រួមមានសុវត្ថិភាពប្រព័ន្ធអេកូឡូស៊ី ការបញ្ចេញសំណល់តិច កាត់បន្ថយការបំពុល ការប្រើប្រាស់និងកែច្នៃឡើងវិញសម្រាប់តម្រូវការនាពេលបច្ចុប្បន្ននិងជំនាន់ក្រោយ។

**ពន្ធបៃតង** សំដៅដល់ពន្ធកាត់បន្ថយការបំពុលបរិស្ថាន ពន្ធបញ្ចេញសំណល់រឹងនិងរាវ ពន្ធប្រើប្រាស់ធនធានធម្មជាតិ ដែលកើតចេញពីសកម្មភាពអភិវឌ្ឍន៍ដែលបំពុលនិងបង្កគ្រោះថ្នាក់ដល់បរិស្ថាន រួមជាមួយការធ្វើអាជីវកម្មនិងការប្រើប្រាស់ធនធានធម្មជាតិ។ ការយកពន្ធបៃតងគឺដើម្បីសម្រេចគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពបរិស្ថាន។

**វិនិយោគបៃតង** សំដៅដល់គម្រោងឬសកម្មភាពវិនិយោគលើការអភិវឌ្ឍបៃតង ដោយផ្តោតលើបច្ចេកវិទ្យាបៃតង សេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បរិស្ថានបៃតងនិងធនធានធម្មជាតិ ធនធានទឹកនិងអនាម័យ សន្តិសុខស្បៀងនិងសុវត្ថិភាពចំណីអាហារ ការប្រើប្រាស់ដីធ្លីប្រកបដោយនិរន្តរភាព គមនាគមន៍ ឧស្សាហកម្មនិងថាមពល និងទេសចរណ៍បៃតង។

**សេដ្ឋកិច្ចខៀវ** សំដៅដល់សកម្មភាពសេដ្ឋកិច្ចដែលកើតចេញពីការអភិវឌ្ឍតំបន់សមុទ្រតាមគោលការណ៍អភិវឌ្ឍន៍បៃតង។

**សេដ្ឋកិច្ចបៃតង** សំដៅដល់ការអភិវឌ្ឍសេដ្ឋកិច្ចប្រកបដោយប្រសិទ្ធភាពនៃការប្រើប្រាស់ធនធានធម្មជាតិ ចីរភាពបរិស្ថាន ការងារបៃតង បច្ចេកវិទ្យាបៃតង និងកំណែទម្រង់សេដ្ឋកិច្ច ដោយគិតគូរបន្ថែមលើការលើកទឹកចិត្តបៃតង ដូចជាពន្ធបៃតង ហិរញ្ញវត្ថុបៃតង ពិសេសឥណទានបៃតង និងមីក្រូហិរញ្ញវត្ថុបៃតងជាដើម។

**ហិរញ្ញវត្ថុបៃតង** សំដៅដល់ឧបករណ៍ហិរញ្ញវត្ថុដូចជា មូលប្បទានបត្រ ភាគហ៊ុន បណ្តូបំណុលជាតិ បណ្តូបំណុលក្រុមហ៊ុន បណ្ណរតនាគារ ទ្រព្យសកម្ម តម្លៃអចលនវត្ថុ ឥណទាន និងធានារ៉ាប់រង ព្រមទាំងទីផ្សារហិរញ្ញវត្ថុដែលលើកកម្ពស់ការទិញដូរផលិតផលបៃតង និងសេវាកម្មបៃតង លើកទឹកចិត្តដល់ការវិនិយោគលើវិស័យកសិកម្មបៃតង ឧស្សាហកម្មបៃតង ពាណិជ្ជកម្មបៃតង ហេដ្ឋារចនាសម្ព័ន្ធនិងការដឹកជញ្ជូនបៃតង ទេសចរណ៍បៃតង ថាមពលបៃតង សំណង់និងអគារបៃតង ទូរគមនាគមន៍បៃតង ការស្រាវជ្រាវនិងការអភិវឌ្ឍវិស័យបៃតង ជំនាញនិងបច្ចេកទេសបៃតង ស្ថាបនាបៃតង កន្លែងធ្វើការងារមានលក្ខណៈបៃតង ទីផ្សារបៃតង ការផ្សព្វផ្សាយផលិតផលបៃតង ការលក់ដូរផលិតផលនិងសេវាកម្មបៃតង ព្រមទាំងលទ្ធកម្មហិរញ្ញវត្ថុបៃតង។

**អភិវឌ្ឍន៍បៃតង** សំដៅដល់ការអភិវឌ្ឍសេដ្ឋកិច្ចប្រកបដោយចីរភាពដែលមិនបង្កការខូចខាតដល់បរិស្ថាន ដោយផ្អែកលើការប្រើប្រាស់ធនធានធម្មជាតិតិចដែលទទួលបានទិន្នផលខ្ពស់ ប្រសិទ្ធភាពថាមពល ការបញ្ចេញសំណល់តិច ការអភិវឌ្ឍស្អាត ការថែរក្សាភាពបៃតងនិងបេតិកភណ្ឌធម្មជាតិ ព្រមទាំងការបង្កើនជីវភាពរស់នៅរបស់ប្រជាជន ដើម្បីសម្រេចបាននូវតុល្យភាពនៃការអភិវឌ្ឍសេដ្ឋកិច្ចជាមួយនឹងនិរន្តរភាពបរិស្ថាន ដែលជាឧត្តមប្រយោជន៍ដល់សង្គមទាំងមូល។

**អភិវឌ្ឍន៍ប្រកបដោយចីរភាព** សំដៅដល់ការអភិវឌ្ឍដែលនាំមកនូវការរីកចម្រើនសេដ្ឋកិច្ចសង្គមប្រកបដោយចីរភាពបរិស្ថាន ដោយផ្អែកលើតុល្យភាពនៃបង្គោលគ្រឹះ០៤ គឺ សេដ្ឋកិច្ច សង្គម បរិស្ថាន និងវប្បធម៌។

**ឧស្សាហកម្មបៃតង** សំដៅដល់ផលិតកម្មស្អាតដែលប្រើប្រាស់បច្ចេកវិទ្យាបៃតង ថាមពលប្រកបដោយប្រសិទ្ធភាព និងកាត់បន្ថយការប្រើប្រាស់ធនធានធម្មជាតិនៅក្នុងខ្សែចង្វាក់ផលិតកម្មនៃសហគ្រាសធុនតូច មធ្យម និងធំ ដើម្បីធានាដល់និរន្តរភាពធនធានធម្មជាតិដោយអនុវត្តគោលការណ៍ផលិតកម្មនិងការប្រើប្រាស់ប្រកបដោយចីរភាព។